ព្រះរាជាណាចក្រកម្ពុជា
*Kingdom of Cambodia*

**ទីស្តីការគណៈរដ្ឋមន្ត្រី**
*Office of the Council of Ministers*
**លេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល**
*Secretariat of the Task Force*

**ជាតិ សាសនា ព្រះមហាក្សត្រ**
*Nation Religion King*

# សេចក្តីប្រកាសព័ត៌មាន
# Press Release

## អំពី

## ពិធីប្រគល់អគារធ្វើការនិងបរិវេណសំរាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ដោយឯកឧត្តម ស៊ាន វិសុទ្ធ ប្រធានការិយាល័យរដ្ឋបាល និងជាលេខាធិការប្រតិបត្តិ**
**ក្រុមការងាររបស់រាជរដ្ឋាភិបាលសំរាប់ការកាត់សេចក្តីខ្មែរក្រហម**

នៅថ្ងៃពុធ ទី១៨ ខែមករា ឆ្នាំ២០០៦នេះមានការប្រារព្ធពិធីប្រគល់ទីកន្លែងមួយផ្នែករបស់អគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ ដែលស្ថិតនៅភូមិកន្ទោក សំរាប់ប្រើប្រាស់ក្នុងដំណើរការកាត់សេចក្តីខ្មែរក្រហម។ អគារចំនួន០២ខ្នង រួមជាមួយបរិវេណជុំវិញអគារនោះ នឹងត្រូវបានប្រើប្រាស់ជាទីតាំងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សំរាប់ការកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាល នៃកម្ពុជាប្រជាធិបតេយ្យ (ECCC)។

ពិធីប្រគល់នេះជាការកត់ចំណាំមួយយ៉ាងសំខាន់ក្នុងប្រវត្តិសាស្រ្តដ៏យូរ នៃការនាំមកនូវភាពទទួលខុសត្រូវចំពោះបទឧក្រិដ្ឋទាំងឡាយ ដែលបានប្រព្រឹត្តក្នុងកំឡុងពេលប្រមាណ៣០ឆ្នាំមុននេះ។ ការកាត់សេចក្តីដែលជិតនឹងមកដល់នេះមានគោលបំណងបីគឺៈ ផ្តល់យុត្តិធម៌ដល់ជនរងគ្រោះនិងជនដែលនៅរស់រានមានជីវិតដើម្បីធ្វើការទប់ស្កាត់អំពើយង់ឃ្នងបែបនេះកុំអោយកើតមានក្នុងពេលអនាគត និងផ្តល់អោយយុវជនជំនាន់ក្រោយនូវរូបភាពប្រត្យក្សអំពីអ្វីដែលបានកើតឡើងរួចមកហើយ។ យុវជនជំនាន់ក្រោយទាំងអស់បានចំរើនវ័យ និងកំពុងតែស្វែងរកពតិមានអំពីអ្វីដែលបានកើតឡើង ហើយនរណាគួរទទួលខុសត្រូវ។

ជំនួសមុខអោយក្រុមការងារដែលមានឯកឧត្តមឧបនាយករដ្ឋមន្ត្រី **សុខ អាន** ជាប្រធាន យើងខ្ញុំសូមសំដែងនូវការកោតសរសើរដល់កងយោធពលខេមរភូមិន្ទ ចំពោះការយល់ព្រមពន្យាពេលបីឆ្នាំក្នុងការប្រើប្រាស់ទីតាំងអគ្គបញ្ជាការថ្មីនេះដែលពួកគេកំពុងទន្ទឹងរង់ចាំ។ ភាគីកម្ពុជា និងភាគីអង្គការសហប្រជាជាតិជឿជាក់ថា នេះជាទីកន្លែងដែលល្អវិសេស សំរាប់ធ្វើជាទីតាំងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា - មានកន្លែងចាំបាច់សំរាប់ការិយាល័យនិងបន្ទប់សវនាការស្ថិតក្នុងបរិវេណតែមួយ លើសពីនេះទៀតគឺ

ប្រកបដោយសុវត្ថិភាពជាង និងជួយកាត់បន្ថយភាពរំខានដល់ប្រជាជនក្នុងក្រុងភ្នំពេញក្នុងកំឡុងពេលនៃដំណើរការជំនុំជម្រះក្តី ។

ឆ្លៀតក្នុងឱកាសនេះដែរយើងខ្ញុំសូមថ្លែងអំណរគុណដល់ប្រទេសជាម្ចាស់អំណោយទាំងអស់ ទាំងចំពោះអ្នកដែលបានចូលរួមវិភាគទានជាថវិកាតាមរយៈអង្គការសហប្រជាជាតិ ទាំងចំពោះអ្នកដែលបានចូលរួមវិភាគទានជាថវិកាតាមរយៈភាគីកម្ពុជា ក្នុងនោះយើងខ្ញុំបានទទួលវិភាគទានពីសហគមន៍អឺរ៉ុបចំនួន ១.២លាន ដុល្លារសហរដ្ឋអាមេរិក និងពីប្រទេសថៃចំនួន ២៥.០០០ដុល្លារសហរដ្ឋអាមេរិក បំពេញបន្ថែមលើវិភាគទានដែលបានទទួលពីប្រទេសឥណ្ឌាចំនួន ១លានដុល្លារសហរដ្ឋអាមេរិក និងពីសំណាក់រាជរដ្ឋាភិបាលកម្ពុជាចំនួន ១.៥លាន ដុល្លារសហរដ្ឋអាមេរិក ។ យើងខ្ញុំមានការជឿជាក់ថា មូលនិធិដែលនៅសេសសល់នឹងត្រូវបានធានាក្នុងពេលឆាប់ៗនេះ ។

យើងខ្ញុំកំពុងបង្កើតក្រុមចាប់ផ្តើមការងាររួមមួយសំរាប់ការិយាល័យរដ្ឋបាល ។ ដៃគូរបស់យើងដឹកនាំដោយ លោកស្រី **មីសែល លី** នាយករងនៃការិយាល័យរដ្ឋបាលមកពីអង្គការសហប្រជាជាតិ នឹងមកដល់ភ្នំពេញក្នុងកំឡុងពេលប៉ុន្មានអាទិត្យខាងមុខនេះ ហើយយើងខ្ញុំមានបំណងនឹងចូលមកធ្វើការក្នុងទីតាំងនេះនាដើមខែកុម្ភៈ បន្ទាប់ពីការកែប្រែក្នុងទ្រង់ទ្រាយតូចបានរួចរាល់ហើយ ។

ចំពោះផ្នែកច្បាប់ និងតុលាការ ដំណាក់កាលចុងក្រោយនៃការតែងតាំងចៅក្រមជាតិ និងអន្តរជាតិសហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេតកំពុងតែដំណើរការ ហើយយើងខ្ញុំរំពឹងទុកថានឹងអាចប្រកាសឈ្មោះរបស់ពួកគេក្នុងពេលដ៏ខ្លីខាងមុខនេះ ។ ការត្រៀមលក្ខណៈផ្សេងៗទៀតក៏កំពុងតែដំណើរការ ដូចជាការចងក្រងប្រមូលឯកសារច្បាប់ជាមូលដ្ឋានជាង ១០០ ជាភាសាផ្លូវការនៅក្នុងតុលាការ (ទទួលការឧបត្ថម្ភពីរដ្ឋាភិបាលប្រទេសន័រវេស) និងកម្មវិធីផ្សព្វផ្សាយពតិមានតាមតំបន់ (ឧបត្ថម្ភពីរដ្ឋាភិបាលប្រទេសអូស្ត្រាលី) ។

ថ្ងៃនេះ បានបញ្ជាក់ច្បាស់ពីការសំរេចលទ្ធផលនៃការរង់ចាំអស់រយៈកាលដ៏យូរ ដើម្បីអោយបង្កើតអោយមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សំរាប់ដំណើរការកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ។

យើងខ្ញុំដឹងថាភារកិច្ចនៅចំពោះមុខរបស់បុគ្គលិក និងមន្ត្រីតុលាការទាំងអស់ ជាកិច្ចការមួយសំខាន់ដែលចាំបាច់ត្រូវប្រើអោយអស់លទ្ធភាពនូវបទពិសោធន៍ ការប្រឹងប្រែងនិងភាពអត់ធ្មត់ ប៉ុន្តែយើងខ្ញុំសន្យាថានឹងខិតខំអោយអស់ពីសមត្ថភាព ដើម្បីទទួលខុសត្រូវនូវរាល់កាតព្វកិច្ចដែលបានចាត់តាំងក្នុងន័យសបញ្ជាក់ថាភាពយឺតយូរក្នុងការរកយុត្តិធម៌ នឹងមិនមានន័យថា មិនមានយុត្តិធម៌សំរាប់ប្រជាជនកម្ពុជានោះទេ ។

កាំបូល
ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០៦